ព្រះនាមចំតើត ៖ ស៊ៃនុល-អ៊ុាប៊ីឌីន អាស់សាច់យ៉ាដ់ ។

ព្រះគារវៈនាម ៖ អាប៊ូ អាល់-ហាសាន់ ។

ព្រះនាមរបស់ព្រះបិតា ៖ អាល់-ហ៊ូសៃន៍ ។

ព្រះនាមរបស់ព្រះមាតា ៖ ស្ហាស់ ស៊ាណាន ។

ព្រះនាមរបស់ព្រះអយ្យកោ ៖ អ៊ុាលី ។

ថ្ងៃប្រសូត ៖ ថ្ងៃទី ៥ ខែស្ហាក់បាន់ ឆ្នាំ ៣៨ សកករាជហ៊ីជ្រ៉ោះត៍ ។

អាណត្តិអ៊ីម៉ាម៉ាស់ ៖ ៣៥ វស្សា ។

ព្រះជន្មនៅពេលទទួលទុក្ករកម្ម ៖ ៥៧ វស្សា ។

ថ្ងៃចូលទិវង្គត (ទទួលទុក្ករកម្ម)៖ ថ្ងៃទី ២៥ ខែមូហារ៉ម ឆ្នាំ ៩៥ សកករាជ ហ៊ីជ្រ៉ោះត៍ ។

កន្លែងបញ្ចុះព្រះរាជសព ៖ ម៉ាឌីណាស់ ។

# ជីវប្រវត្តរបស់ អ៊ីម៉ាំអ៊ុាលី អាស់សាច់យ៉ាដ់ صلوات الله عليه والسلام



សៃយីដ ម៉ាស់ឌី អាយ៉ាទុលឡ៏ហ៊ី

ស្ហាគីប បេនបេឌីវ៉ា

នេះដូចរូបបំភាន់ភ្នែក គេនឹងថាជិតអ្វីដែលឆ្ងាយ គេនឹងថាឆ្ងាយអ្វីដែលជិត ។ ចូរប្រយ័តបុគ្គលកំហូច គេនឹងលក់កូនដូរបាយមួយពេល ឬដូរអ្វីដែលថោកជាងនោះ ។ ចូរប្រយ័តបុគ្គលកំណាញ់ គេនឹងចោលកូនពេលដែលកូនត្រូវការគេបំផុត ។ ចូរប្រយ័តបុគ្គលភ្លីភ្លើ គេចង់ធ្វើល្អដាក់កូន តែគេធ្វើអាក្រក់ទេ ។ ចូរប្រយ័តបុគ្គលដែលផ្តាច់ទំនាក់ទំនងសាច់សាលោហិត ឪពុកឃើញមានចែងនៅក្នុងព្រះគម្ពីរថាបុគ្គលនោះត្រូវបណ្តាសាអល់ឡោះហ៍ عزّ وجلّ ។»

អ៊ីម៉ាំអាស់សាច់យ៉ាដ់ صلوات الله عليه والسلام មានវចនៈប្រាប់អ៊ីម៉ាំអាល់-បាគៀរ صلوات الله عليه والسلام បុត្រព្រះអង្គ صلوات الله عليه والسلام ថា៖ «ចូរកូនប្រព្រឹត្តល្អចំពោះបុគ្គលណាដែលសូមកូន ។ បើបុគ្គលនោះសមនឹងបានការប្រព្រឹត្តល្អមែន ទង្វើរបស់កូនជាទង្វើត្រឹមត្រូវ ។ បើបុគ្គលនោះមិនសមនឹងបានការប្រព្រឹត្តល្អទេ ខ្លួនកូនជាអ្នកសមនឹងបានការប្រព្រឹត្តល្អ ។ បើបុគ្គលណាមើលងាយកូននៅខាងស្តាំដៃកូន ហើយទៅខាងឆ្វេងដៃកូនដើម្បីសូមទោសកូន ចូរកូនទទួលការសូមទោសគេ ។»

## អត្តសញ្ញាណរបស់អ៊ីម៉ាំ

ព្រះនាម ៖ អ៊ាលី ប៊ិន អាល់ ហ៊ូសែន ។

*ឪពុកម្តាយ សិទ្ធិរបស់គ្រូ ។ល។ ចំបងគេបង្អស់គឺសិទ្ធិរបស់ព្រះទ្រង់អ្នកបង្កើត* عزّ وجلّ *។ ឧទាហរណ៍សិទ្ធិរបស់គ្រូ មានចែងដូចតទៅគឺ៖* "សិទ្ធិរបស់គេគឺអ្នកត្រូវគោរពគេ និងជំនួយការរបស់គេ។ អ្នកត្រូវស្តាប់គេឲ្យច្បាស់ អ្នកមិនប្រើសម្តីធំដាក់គេទេ។ អ្នកត្រូវបិទបាំងតំណិះគេ ត្រូវលើកតម្កើងគុណសម្បត្តិគេ។"

*ពាក់ពាន់នឹងសិទ្ធិម្តាយ គឺមានចែងថា៖* "ពាក់ព័ន្ធនឹងសិទ្ធិម្តាយ ចូរអ្នកដឹងថាម្តាយបានពអ្នកក្នុងពោះ បានបំប៉នអ្នកដោយបណ្តូលចិត្ត។ ម្តាយអ្នកសុខចិត្តអត់ឃ្លានឲ្យតែអ្នកបានបរិភោគឆ្អែត សុខចិត្តស្លៀកពាក់កណ្តាចឲ្យតែអ្នកបានស្លៀកពាក់ស្អាតបាត..."

*ពាក់ព័ន្ធនឹងសិទ្ធិអ្នកជិតខាង គឺមានចែងថា៖* "ចូរអ្នកចាត់ទុកថាគេអវត្តមាន។ ចូរអ្នកផ្តល់កិត្តិយសឲ្យគេពេលមានវត្តមាន។ ចូរអ្នកកុំច្រណែនចង់បានឧបការរបស់គេ (ការទំនុកបម្រុងដែលគេបានទទួលមកពីអល់ឡោះហ្វ៍)។ ចូរអ្នកកុំផ្តោតទៅលើកំហុសគេ ចូរអ្នកអភ័យទោសឲ្យគេដែលបានប្រព្រឹត្តខុស។"

## វចនៈត្រចះត្រចង់

*អ៊ីមុាំអាស់សាច់យ៉ាជ៉ុំ* صلوات الله عليه والسلام *មានវចនៈថា៖ «កូនអើយ ចូរប្រយ័តបុគ្គលប្រាំប្រភេទ។ ចូរកូនកុំនិយាយជាមួយពួកគេជាដាច់ខាតនិងកុំដើរតាមពួកេគជាដាច់ខាត។ ចូរកូនប្រយ័តខ្លួន បើកូនជាមិត្តរបស់បុគ្គលនិយាយកុតករ បុគ្គល*



# បញ្ជីមាតិកា


សីលធម៌និងគុណសម្បត្តិ ....................7
នៅពីមុខការកាប់សម្លាប់នៅការបាឡាអ៊ុំ ....................16
ជាមួយឈ្លើយសឹក ....................17
នៅឯវាំងអភិបាលក្រុង ....................19
ទៅកាន់ដាម៉ាស់ ....................22
អ៊ីម៉ាំ صلوات الله عليه والسلام តទល់យ៉ាស៊ីដ្ន ....................25
សម័យអស្ថិរភាពនយោបាយ ....................30
អ៊ីម៉ាំនិងអាប់ឌុល-ម៉ាលិក ....................32
ប្រឈមមុខនឹងហ៊ីស្សាំ ....................34
អ៊ីម៉ាំត្រូវថ្នាំបំពុល ....................36
មរតកពិសិដ្ឋ ....................38
មូលបទក្នុងតម្រាសាច់យ៉ាឌីន ....................39
តម្រាច្បាប់ ....................41
វចនៈគ្រចះគ្រចង់ ....................42
អត្តសញ្ញាណរបស់អ៊ីម៉ាំ ....................43




# តម្រាច្បាប់

*សម័យដែលកំពុងតែមានទំនាក់ទំនង ជាមួយអារ្យធម៌ចាញ់សង្គ្រាមពីរ គឺអរិយធម៌រូម (ឬ រូម៉ាំង) និងអរិយធម៌សាសានីយ៉ាន់ (ساسانیان) ជាសញ្ញាប្រាប់ឲ្យដឹងជាមុនថានឹងមានចលាចលខ្លាំងក្នុងអនាគត ។ ដូច្នេះអ៊ីម៉ាំ អាស់លុល-បៃត៍ عليهم السلام ខិតខំថែរក្សាតម្លៃសាសនាអ៊ីស្លាម ។*

*ការចងក្រងច្បាប់ជាលាយលក្ខអក្សរ មិនមែនជាទំនៀមទម្លាប់របស់ពួកអារ៉ាប់ទេនាសម័យអ៊ីម៉ាំអាលី សែុនុល-អាប៊ីឌីន អាស់សាច់យ៉ាដ្ន صلوات الله عليه والسلام ។ ត្រូវពឹងលើលោកអ្នកចេះដឹងច្បាប់អ៊ីស្លាម បើចង់ស្គាល់សិទ្ធិនិងកាតព្វកិច្ចរបស់បុគ្គលនីមួយៗ ។*

*អ៊ីម៉ាំអាស់សាច់យ៉ាដ្ន صلوات الله عليه والسلام បានបំពេញកង្វះខាតនេះ ដោយចងក្រងតម្រាច្បាប់ ។ នៅក្នុងតម្រាច្បាប់នេះ ព្រះអង្គ صلوات الله عليه والسلام រំលឹកឡើងវិញអំពីសិទ្ធិនានាដែលបុគ្គលរាល់គ្នាត្រូវមានឬត្រូវផ្តល់ឲ្យទៅគេ ។*

*តម្រាច្បាប់មាន ៥០ មាត្រា ។ មាត្រានីមួយៗចែងអំពីសិទ្ធិនិងកាតព្វកិច្ចរបស់មុស្លីម ដោយមានកំណត់និងមានព្រំដែនច្បាស់លាស់សម្រាប់ជីវិតរស់នៅ ។ ដូច្នេះគេឃើញមានមាត្រាស្តីអំពីសិទ្ធិរបស់អ្នកជិតខាង សិទ្ធិរបស់*

ឃើញហេតុផលប្រកដដោយគំនិត ។ ចំណែកឯទស្សនៈវិទូក៏ច្បាស់ជានឹងឃើញថាតម្រានេះជាឃ្លាំងនៃគំនិត និងនៃការបកស្រាយទស្សនៈស្តីអំពីមនុស្ស អំពីភពផែនដែនចក្រវាលនិងអំពីជីវិត ។ លោកអ្នកប្រាជ្ញច្បាស់ជានឹងដក់ស្លុងងើបក្បាលមិនរួចទេ ។ គេអាចដកស្រង់បានពីអត្ថបទបួងសួងទាំងនេះនូវមូលបទ (គោលរឿង) នានាដូចតទៅ៖

-បទបួងសួងប្រចាំថ្ងៃ ។ ថ្ងៃនីមួយៗក្នុងសប្តាហ៍មានបទបួងសួងដាច់ឡែកមួយ ។

-បទបួងសួងប្រចាំសញ្ញាធម្មជាតិ (ឬអព្ភូតហេតុអស្ចារ្យ) ។ សញ្ញាមួយ ឬអព្ភូតហេតុអស្ចារ្យមួយមានបទបួងសូងមួយ ។

-បទសន្ទនា មាន ១៥ បទ ។

-មូលបទផ្សេងៗ ។

សូមបញ្ជាក់ថា បកប្រែបទបួងសួងទាំងនេះជាភាសាដទៃអាចធ្វើឲ្យបាត់បង់នូវសោភ័ណភាពរបស់វា ។ វាគ្រាន់តែជាការទាញន័យនិងជាការអធិប្បាយប៉ុណ្ណោះ មិនមែនន័យពិតប្រាកដទេ ។ ទោះជាយ៉ាងណាក៏ដោយ ត្រូវចេះបន្លឺសម្លេងពាក្យឲ្យបានត្រឹមត្រូវ បំណាច់ត្រូវសូត្របទបួងសួងទាំងនេះជាភាសាអារ៉ាប់ ។





# កំណើត

នាសម័យខ៊ិលិហ្វអ៊ុម៉ារ ខ៊ិលិហ្វមុស្លីមទីពីរ ភាគីមុស្លីមបានវាយយកបាន អាណាចក្រពែរស៍ (Perse ឬ Persia) ។ យោលតាមទំនៀមទម្លាប់អន្តរជាតិ សម័យនោះ ពួកមុស្លីមបាននាំឈ្លើយសឹកមកជាមួយផង ពេលត្រឡប់មក ស្រុកវិញ ដើម្បីយកមកលក់នៅឯរាជធានីមុស្លីមម៉ាឌីណាស្ទុំ ។ ឈ្លើយសឹក ទាំងនោះមានប្រុស ស្រីនិងក្មេង គ្រប់ស្រទាប់វណ្ណៈ ។ ស្ហាស្ទុំ ស្ហាណាន់ (شاه زنان ឬ ស្ហាស្ទុំបានូ شهر بانو) រាជធីតារបស់អធិរាជ ពែរស៍ យ៉ាស្ទុំដ្ដាយៀរដ្ដ (يزدجرد) ជាឈ្លើយសឹកមួយរូបដែរ ក្នុងចំណោមឈ្លើយសឹកទាំងនោះ ។ យោលតាមបញ្ញារបស់អ៊ុម៉ារ ត្រូវយកព្រះនាងទៅលក់ដូចអ្នកដទៃដែរ ។

អ៊ីម៉ាំអ៊ាលី صلوات الله عليه والسلام បានធ្វើអន្តរាគមន៍ដើម្បីរំលឹកខ៊ិលិហ្វទីពីរថា ច្បាប់ហាម ដួញដូររាជវង្ស គប្បីរៀបអាពាហ៍ពិពាហ៍បុត្រីរបស់ព្រះចៅអធិរាជជាមួយ បុរសមុស្លីមដែលព្រះនាងជ្រើសរើសដោយខ្លួនឯងប្រសើរជាង គឺបុរស ដែលព្រមលោះខ្លួនព្រះនាងឲ្យរួចផុតពីពន្ធប្រចាំឆ្នាំ ដើម្បីព្រះនាងនឹងមាន សេរីភាព ។ ស្ហាស្ទុំ ស្ហាណាន់បានចៀសផុតពីទាសៈភាពដូច្នេះឯង ហើយ បានក្លាយទៅជាមហេសីរបស់អ៊ីម៉ាំអាល់-ហ៊ូសៃន៍ صلوات الله عليه والسلام ដែលព្រះនាងបាន



នីមួយៗគេឃើញមានទស្សនៈប្រៀនប្រដៅរបស់អ៊ីស្លាមពិតប្រាកដ ។ ដូច្នេះ អាស្រ័យលើវិធីប្លែកពីគេនេះ អ៊ីម៉ាំអាស់សាច់យ៉ាដ់ صلوات الله عليه والسلام បានសម្រេចក្នុង ការអភិរក្សជំនឿពិត ហើយម្យ៉ាងទៀតព្រះអង្គ صلوات الله عليه والسلام បង្ហាត់បង្រៀនយើងឲ្យ ចេះរបៀបនិយាយរកព្រះអ្នកបង្កើត عز وجل យើង ។ ដូច្នេះព្រះអង្គ صلوات الله عليه والسلام បាន សម្រេចគោលដៅពីរគឺៈ បង្ហាត់បង្រៀននិងអប់រំ ។

# មូលបទក្នុងតម្រាសាច់យ៉ាឌីន

អធិប្បាយតម្រាសាច់យ៉ាឌីនមិនជាការងាយស្រួលទេ ។ មានតែបទ បួងសួងនីមួយៗផ្ទាល់ប៉ុណ្ណោះ ដែលអាចធ្វើអត្ថាធិប្បាយបទបួងសួងនីមួយៗ នោះបាន ។ មិនអាចពោលសង្ខេបបានទេ ព្រោះពាក្យនីមួយៗមានន័យដាច់ ទៀត មិនអាចផ្លាស់ប្តូរបានទេ ។ អ្នកឯកទេសអក្សរសាស្ត្រអារ៉ាប់បានឲ្យ ដឹងថាតម្រានេះផ្ទុកនូវកំណាប់អក្សរសាស្ត្រដ៏មានតម្លៃ ។ អ្នកឯកទេសខាង តក្កវិជ្ជានិងខាងការប៉ិនប្រសប់វិភាគ ច្បាស់ជានឹងឃើញមានការរៀបពាក្យ ក្នុងប្រយោគដែលគួរឲ្យស្ញើចអនេក គឺមានការស្រាយបំភ្លឺនិងការត្រិះរិះឲ្យ

អ៊ីម៉ាំអ៊ុាលី ប៊ិន អាល់-ហ៊្វ៊ុសែន៍ ស៊ៃនុល-អ៊ុាប៊ីឌីន អាស់សាច្ជ់យ្ជ៉ាដ្ដ់ صلوات الله عليه والسلام បានចូលទិវង្គតថ្ងៃទី ២៥ ខែមូហារ៉ម ឆ្នាំ ៩៥ សករាជហ៊ិជ្ជរ៉ោះត្ត៍ ។ ព្រះរាជសពព្រះអង្គ صلوات الله عليه والسلام ត្រូវបញ្ចុះនៅឯស្មសានអាល់-បាគ្គីអ៊ុ (البقيع) ក្បែរផ្នូរព្រះមាតុលា(ឪពុកធំ)របស់ព្រះអង្គ صلوات الله عليه والسلام អ៊ីម៉ាំអាល់-ហាសាន់ صلوات الله عليه والسلام ។

សូមសិរីសួស្តីជ័យមង្គល កើតមានដល់វិញ្ញាណបរិសុទ្ធរបស់ព្រះអង្គ صلوات الله عليه والسلام និងដល់សុក្រឹតបុគ្គលអាស្ហុលុល-បៃត៍ عليهم السلام ទាំងអស់ ។

## មរតកពិសិដ្ឋ

មុស្លីមទាំងឡាយប្រហែលជាស្គាល់តម្រាមួយ ដែលមានចំណងជើងថា “អាស្ហ្ស៊ហ៊ីហ្វាស្ហ៍ អាស់សាច្ជ់យ្ជ៉ាឌីយ៉ាស្ហ៍ (الصحيفه السجاديه)” មានន័យត្រង់ថា “តម្រាសាច្ជ់យ្ជ៉ាឌីន” ពោលគឺ សៀវភៅដែលចងក្រងនិពន្ធដោយអ៊ីម៉ាំអាស់សាច្ជ់យ្ជ៉ាដ្ដ់ صلوات الله عليه والسلام ផ្ទាល់ ។

តម្រានេះប្រជុំបទបួងសួងច្រើនដែលមានអត្ថន័យប្លែកពីការបួងសួង និងការបន់ស្រន់ធម្មតា ។ អ៊ីម៉ាំអាស់សាច្ជ់យ្ជ៉ាដ្ដ់ صلوات الله عليه والسلام មានគោលបំណងចងក្រងសិក្ខាបទរបស់ព្រះអង្គ صلوات الله عليه والسلام ឡើងតាមរយៈបទបួងសួង ។ នៅក្នុងបទបួងសួង



ជ្រើសក្នុងចំណោមបុរសមុស្លីមទាំងឡាយ ។ កាលអ៊ីម៉ាំអាល់-ហ៊្វ៊ុសែន៍ صلوات الله عليه والسلام បានអភិសេកជាមួយស្ហាស្ហ៍ ស្ហ៊ាណាន់ អ៊ីម៉ាំអ៊ុាលី صلوات الله عليه والسلام ព្រះបិតាព្រះអង្គ صلوات الله عليه والسلام បានប្រាប់ព្រះអង្គ صلوات الله عليه والسلام ថា៖ «អាប៊ូ អ៊ុាប់ឌុលឡោះហ្វ៍អឺយ ព្រះនាងនឹងប្រសូតបុត្រឲ្យកូន صلوات الله عليه والسلام ដែលជាបុរសប្រសើរលើសគេនៅលើផែនដី ។» មែន ស្ហាស្ហ៍ ស្ហ៊ាណាន់បានប្រសូតព្រះរាជទារកដែលប្រកបដោយកិត្យានុភាពក្រៃលែង ដែលជាបុគ្គលសុក្រឹតឥតខ្ចោះទីប្រាំមួយនិងជាទាយាទរបស់អ៊ីម៉ាំអាល់-ហ៊្វ៊ុសែន៍ صلوات الله عليه والسلام ដែលមានព្រះនាមថា អ៊ុាលី ប៊ិន អាល់-ហ៊្វ៊ុសែន៍ អ៊ីម៉ាំទីបួននិងជាព្រះឧត្តរាធិការីរបស់ព្រះសាស្តា صلى الله عليه وآله وسلم ។ អ៊ីម៉ាំអាល់-ហ៊្វ៊ុសែន៍ صلوات الله عليه والسلام បានដាក់ព្រះនាមចំតើតឲ្យព្រះរាជបុត្រព្រះអង្គ صلوات الله عليه والسلام ថា ព្រះរាជកុមារនៃជម្រើសល្អទាំងពីរ ព្រោះមាតាព្រះអង្គជារាជវង្សព្រះចៅអធិរាជពែរ្ស ដែលគេចាត់ទុកថាជាប្រជារាស្ត្រមិនមែនអារ៉ាប់ដែលប្រសើរបំផុត រីឯព្រះបិតាព្រះអង្គជាបានី-ហាស្ហ៊ីមដែលគេចាត់ទុកថាជាត្រកូលគូ្ហរ៉យ៉ស្ហ៍ដែលប្រសើរបំផុត ហើយកុលសម្ព័ន្ធគូ្ហរ៉យ៉ស្ហ៍ជាកុលសម្ព័ន្ធប្រសើរជាងកុលសម្ព័ន្ធអារ៉ាប់ទាំងអស់ ។

## សីលធម៌និងគុណសម្បត្តិ





ដោយពរជ័យសិរីសួស្តី ។ ស្ថានការណ៍នេះធ្វើឲ្យសំណាក់អ៊ូម៉ៃយ៉ាស្ងប់ភ័យរន្ធត់ ជាពិសេសអាល់-វ៉ាលីដ្ឋ ប៊ិន អុាប់ឌុលម៉ាលិក ហោហុីស្សាំ ដែលប្រកបដោយព្យាបាទបំផុតមកលើអ៊ីម៉ាំ صلوات الله عليه والسلام ។ អាល់-ស៊ុះហ្ទរី (الزهري) បានធ្វើសេចក្តីរាយការណ៍អំពីអាល់-វ៉ាលីដ្ឋ ប៊ិន អុាប់ឌុលម៉ាលិកដែលបានថា៖ «ដរាបណា អុាលី ប៊ិន អាល់-ហ៊ូសែន صلوات الله عليه والسلام នៅក្នុងលោកនេះ ខ្ញុំមិនអាចស្រាកស្រាន្តបានទេ ។» (ហ្ហាយ៉ាត្ត់ អាល់-អ៊ីម៉ាំ មូហ្ហាំម៉ាដ្ឋ អាល់-បាគ្គៀរ ក្បាលទី ១ ទំព័រ ៥១)

លុះបានឡើងសោយរាជ្យ អាល់-វ៉ាលីដ្ឋសម្រេចចិត្តធ្វើគុតអ៊ីម៉ាំ صلوات الله عليه والسلام ។ អាល់-វ៉ាលីដ្ឋបានផ្ញើថ្នាំបំពុលទៅឲ្យអភិបាលក្រុងម៉ាឌីណាស្ង់ បញ្ជាលាយថ្នាំបំពុលជាមួយភេសជ្ជឲ្យអ៊ីម៉ាំ صلوات الله عليه والسلام សោយ ។ ថ្នាំបំពុលបានជ្រួតជ្រាបចូលព្រះកាយអ៊ីម៉ាំ صلوات الله عليه والسلام ។ ព្រះអង្គ صلوات الله عليه والسلام រងការឈឺចាប់ជាទីបំផុត ដើបទៅណាមិនរួច អស់ច្រើនថ្ងៃ ។ ព្រះអង្គ صلوات الله عليه والسلام បានប្តឹងអល់ឡោះហ៍ عز وجل ពីរឿងនេះ ហើយបានសូមខមាទោសចំពោះព្រះអង្គ ។ ប្រជារាស្ត្របានមកមើលព្រះអង្គ صلوات الله عليه والسلام យ៉ាងកុះករ ។ ព្រះអង្គ صلوات الله عليه والسلام បានគោរពសក្ការៈនិងថ្វាយសេចក្តីសរសើរចំពោះ អល់ឡោះហ៍ عز وجل ដែលបានឲ្យព្រះអង្គ صلوات الله عليه والسلام ធ្វើទុក្ករកម្ម(បូជាព្រះជន្ម) នៅក្នុងដៃបុគ្គលអប្រិយលើសអស់សត្វលោក ។

ការគោបសង្កត់នេះ តាមរយៈបទបួងសួងល្បីៗរបស់ព្រះអង្គ صلوات الله عليه والسلام ដែលប្លែកពីគេ ដែលសម្បូរធម៌និងទ្រឹស្តីក្រៃលែង ។

កេរ្តិ៍ឈ្មោះអ៊ីម៉ាំអាស់សាច់យ៉ាដ៉ុ صلوات الله عليه والسلام វិសេសវិសាលបំផុត ។ ទោះបីព្រះអង្គ صلوات الله عليه والسلام មិនមានអំណាចនយោបាយបន្តិចក៏ដោយ មុស្លីមទាំងអស់គោរពព្រះអង្គ صلوات الله عليه والسلام ហាក់ដូចជាព្រះអង្គ صلوات الله عليه والسلام ជាស្តេចសោយរាជ្យមួយអង្គ ។

## អ៊ីម៉ាំត្រូវថ្នាំបំពុល

អ៊ុាលី ប៊ិន អាល់-ហ៊ុសៃន៍ ហ្សៃនុល-អ៊ុាប៊ីឌីន អាស់សាច់យ៉ាដ៉ុ صلوات الله عليه والسلام សម្បូរប្រិយភាពណាស់ ។ មនុស្សទូទៅតែងតែស្ញើចចំណេះចេះដឹងរបស់ព្រះអង្គ صلوات الله عليه والسلام យុត្តិសាស្ត្រក្នុងវិស័យសាសនារបស់ព្រះអង្គ صلوات الله عليه والسلام និងការគោរពសក្ការៈរបស់ព្រះអង្គ صلوات الله عليه والسلام ។ គេតែងតែស្ញើចសរសើរការអត់ធ្មត់និងគុណសម្បត្តិឯទៀតរបស់ព្រះអង្គ صلوات الله عليه والسلام ។ អ៊ីម៉ាំ صلوات الله عليه والسلام ជិតជាប់នៅក្នុងបេះដូងនិងក្នុងអារម្មណ៍របស់ប្រជារាស្ត្រ ។ ដូច្នេះ អ្នកណាបានឃើញព្រះអង្គ صلوات الله عليه والسلام បានជួបព្រះអង្គ صلوات الله عليه والسلام និងបានស្តាប់ព្រះវចនៈព្រះអង្គ صلوات الله عليه والسلام អ្នកនោះប្រែកប



កវីអារ៉ាប់ល្បីម្នាក់ឈ្មោះ អាល់-ហ្វារ៉ុស្ដាក់ (الفرزدق) បានថ្លែងពិពណ៌នាអំពីអ៊ីម៉ាំ ប៊ិន អាល់-ហ៊ុសៃន៍ صلوات الله عليه والسلام ថា៖ ព្រះអង្គ صلوات الله عليه والسلام មានទឹកមុខស្រស់បស់បំផុតនិងមានក្លិនក្រអូបបំផុត ។ នៅចន្លោះភ្នែកទាំងពីរមានស្នាមក្រាបប្រណិប័តន៍ អាស្រ័យហេតុនេះឯងបានជាគេហៅព្រះអង្គ صلوات الله عليه والسلام ថា អ្នកក្រាបប្រណិប័តន៍ (السجاد អាស់សាច់យ៉ាដ៉ុ) ។ អ៊ីម៉ាំមូហាំម៉ាដ់ អាល់-បាគៀរ صلوات الله عليه والسلام បានរៀបរាប់អំពីព្រះបិតាព្រះអង្គ صلوات الله عليه والسلام ថា៖ «ពេលរដូវរងាបានកន្លងផុតទៅ ព្រះអង្គ صلوات الله عليه والسلام ឲ្យសំលៀកបំពាក់រងាររបស់ព្រះអង្គ صلوات الله عليه والسلام ទៅគេ ។ លុះរដូវក្តៅបានកន្លងផុតទៅ ព្រះអង្គ صلوات الله عليه والسلام ឲ្យសំលៀកបំពាក់រដូវក្តៅទៅគេ ។ ព្រះអង្គ صلوات الله عليه والسلام ធ្វើដូច្នេះដែរជាមួយសំលៀកបំពាក់ឯទៀតរបស់ព្រះអង្គ صلوات الله عليه والسلام ។»

អ៊ីម៉ាំអាស់សាច់យ៉ាដ៉ុ صلوات الله عليه والسلام ស្លៀកពាក់ស្អាតបាតជានិច្ច ។ រាល់ពេលព្រះអង្គ صلوات الله عليه والسلام ងើបពីដំណេកដើម្បីបំពេញនមស្ការ ព្រះអង្គ صلوات الله عليه والسلام ងូតទឹកនិងលាបទឹកអប់ ។ គេស្គាល់ព្រះអង្គ صلوات الله عليه والسلام ព្រោះតែព្រះអង្គ صلوات الله عليه والسلام បួងសួងញឹកញយណាស់ ។ តាវ៉ុស អាល់-យ៉ាម៉ានី (طاووس اليماني) សាវកម្នាក់របស់អ៊ីម៉ាំអាស់សាច់យ៉ាដ៉ុ صلوات الله عليه والسلام បានថា៖ «ខ្ញុំបានឃើញបុរសម្នាក់ធ្វើនមស្ការនៅក្នុងម៉ាស់យ៊ិដពិសិដ្ឋព្រមទាំងបួងសួងដោយយំយែក ។ ខ្ញុំបានចូលទៅជិតបុរស

នោះហើយបានស្គាល់បុរសនោះគឺ អុាលី ប៊ិន អាល់-ហ៊្វៃសេន៍ សៃុនុល-អុាប៊ីឌីន អាស់សាច្ជ់យ្ជ៉ាដ្ដ់ صلوات الله عليه والسلام (علي بن الحسين زين العابدين السجاد)។ ខ្ញុំបានទូលព្រះអង្គ صلوات الله عليه والسلام ថា៖ «បុត្ររ៉សូលុលឡោះហ៍ صلى الله عليه وآله وسلم អឺយ ព្រះអង្គ صلوات الله عليه والسلام ទទួលស្គាល់ថ្មីបើ ព្រះអង្គ صلوات الله عليه والسلام ជាពជបុត្ររបស់ព្រះសាស្ដា صلى الله عليه وآله وسلم ?» ព្រះអង្គ صلوات الله عليه والسلام បានតបថា៖ «ខ្ញុំ صلوات الله عليه والسلام ជាបុត្ររបស់រ៉សូលុលឡោះហ៍ صلى الله عليه وآله وسلم មែន តើមានអ្វីធានាខ្ញុំ صلوات الله عليه والسلام ថាអាចចៀសផុតពីទណ្ឌកម្មអល់ឡោះហ៍ عز وجل បាន ? អល់ឡោះហ៍ عز وجل មិនមានព្រះបន្ទូលទេឬថា៖ "[២៣:១០១] នឹងពុំមានសម្ព័ន្ធភាពសាច់សាលោហិតទេក្នុងថ្ងៃនោះ ។" អល់ឡោះហ៍ عز وجل បង្កើតឋានសួគ៌សម្រាប់អ្នកគោរពសក្ការៈព្រះអង្គ عز وجل និងប្រព្រឹត្តល្អ ទោះជាអ្នកនោះជាទាសៈខ្មៅក៏ដោយ ។ ព្រះអង្គ عز وجل បង្កើតនរកសម្រាប់អ្នកប្រព្រឹត្តខុសចំពោះព្រះអង្គ عز وجل និងធ្វើអំពើអាក្រក់ ទោះជាអ្នកនោះជាម្ចាស់ពួកគ្រួរ៉យស្ហ៍ក៏ដោយ ។»

អ៊ីមុាំអាស់សាច្ជ់យ្ជ៉ាដ្ដ់ صلوات الله عليه والسلام បានទៅបំពេញពិធីហាជ្ជដោយថ្មើរជើង ២៣ ដង ។ ព្រះអង្គ صلوات الله عليه والسلام បានបញ្ជាឲ្យបណ្ដាសាវកព្រះអង្គ صلوات الله عليه والسلام ឲ្យបញ្ញើទៅម្ចាស់បញ្ញើវិញថា៖ «ខ្ញុំ صلوات الله عليه والسلام សូមស្បថចំពោះព្រះដែលបានចាត់បញ្ជូនមូហាំម៉ាដ្ដ់ صلى الله عليه وآله وسلم មកដោយសេចក្ដីពិតថា ប្រសិនបើឃាតកររបស់អាល់-ហ៊្វៃសេន៍ صلوات الله عليه والسلام បានផ្ញើដាវដែលបានសម្លាប់ព្រះអង្គ صلوات الله عليه والسلام ទុកនឹងខ្ញុំ صلوات الله عليه والسلام ខ្ញុំ صلوات الله عليه والسلام នឹង





សាសនាទាំងអស់ឯទៀតនោះដែរ ។

ទោះជាអ៊ីម៉ាំអាស់សាជ្ជ៉ាដ់ صلوات الله عليه والسلام មិនលូកដៃក្នុងរឿងអំណាច និងក្នុងសង្គ្រាមនយោបាយទេក្តី ព្រះអង្គ صلوات الله عليه والسلام ត្រូវចាប់ខ្លួនបញ្ជូនទៅឯដាម៉ាស់ ទៅជួបអ៊ុាប់ឌុលម៉ាលិក ប៊ិន ម៉ារវ៉ាន បន្ទាប់មកត្រូវដោះលែងឲ្យមកកាន់ម៉ាឌីណាស្ញ់វិញ ។

## ប្រឈមមុខនឹងហ៊ីស្សាំ

បន្ទាប់ពីអ៊ុាប់ឌុលម៉ាលិក ប៊ិន ម៉ារវ៉ានបានស្លាប់ទៅ កូនរបស់អ៊ុាប់ឌុលម៉ាលិក ប៊ិន ម៉ារវ៉ានឈ្មោះហ៊ីស្សាំ (ឬ អាប៊ូ អាល់-វ៉ាលីដ្ឋ ហ៊ីស្សាំ ប៊ិន អ៊ុាប់ឌុល-ម៉ាលិក أبو الوليد هشام بن عبد الملك) បានឡើងកាន់អំណាចដើម្បីបន្តនយោបាយឪពុកខ្លួន គឺ៖ បង្ក្រាបឥតអាណិតអាសូរគូប្រឆាំងនយោបាយដែលហ៊ានតវ៉ា រឹតបន្តឹងនិងត្រួតពិនិត្យគូប្រឆាំងដែលមិនហ៊ានតវ៉ាយ៉ាងតឹងរ៉ឹង ។

ប្រវត្តិសាស្ត្របានឲ្យដឹងថា អ៊ីម៉ាំអាស់សាជ្ជ៉ាដ់ صلوات الله عليه والسلام មិនដែលចៀសផុតពីការត្រួតពិនិត្យរបស់ពួកស៊ើបការណ៍សម្ងាត់របស់ហ៊ីស្សាំឡើយ តែព្រះអង្គ صلوات الله عليه والسلام នៅតែអាចផ្សាយគោលសិក្ខាបទអ៊ីស្លាមបានយ៉ាងស្ងៀមស្ងាត់ នៅក្នុង



ប្រគល់ដាវនោះឲ្យទៅឃាតករនោះវិញ ។» ព្រះអង្គ صلوات الله عليه والسلام បានផ្តាំផ្ញើជានិច្ចឲ្យជួយទ្រទ្រង់ជនទាល់ក្រថា៖ «អល់ឡោះហ៍ عز وجل មានអ្នកកក្តីដែលព្យាយាមដោះស្រាយបញ្ហារបស់មនុស្ស ។ ជនទាំងនេះឯងដែលនឹងមានសុវត្ថិភាពក្នុងថ្ងៃរស់ពីស្លាប់ឡើងវិញ ។ អ្នកណាបានធ្វើឲ្យអ្នកមានសទ្ធាសប្បាយចិត្ត អល់ឡោះហ៍ عز وجل នឹងធ្វើឲ្យអ្នកនោះសប្បាយចិត្ត ក្នុងថ្ងៃរស់ពីស្លាប់ឡើងវិញ ។»

ថ្ងៃមួយ កាលអ៊ីម៉ាំ صلوات الله عليه والسلام បានអង្គុយជាមួយបណ្តាសាវកព្រះអង្គ صلوات الله عليه والسلام បងប្អូនជីដូនមួយម្នាក់របស់ព្រះអង្គ صلوات الله عليه والسلام បានមកជេរប្រទេចព្រះអង្គ صلوات الله عليه والسلام ។ អ៊ីម៉ាំ صلوات الله عليه والسلام មិនបានតបតទេ ទាល់តែបុគ្គលនោះត្រឡប់ទៅវិញ ។ បន្ទាប់ពីនោះព្រះអង្គ صلوات الله عليه والسلام បានប្រាប់បណ្តាសាវកព្រះអង្គ صلوات الله عليه والسلام ថា៖ «អស់លោកបានឮបុរសនោះថាអ្វីហើយមែនទេ ? ខ្ញុំ صلوات الله عليه والسلام ចង់ឲ្យអស់លោកទៅជាមួយខ្ញុំ صلوات الله عليه والسلام ដើម្បីស្តាប់ចម្លើយខ្ញុំ صلوات الله عليه والسلام ។» ពួកគេបានទៅជាមួយព្រះអង្គ صلوات الله عليه والسلام គិតថាព្រះអង្គ صلوات الله عليه والسلام នឹងសងសឹកអ្នកឈ្លានពានមកលើព្រះអង្គ صلوات الله عليه والسلام ។ មកដល់ផ្ទះបងប្អូនជីដូនមួយរបស់ព្រះអង្គ صلوات الله عليه والسلام ដែលមានគំនុំ ព្រះអង្គ صلوات الله عليه والسلام បានគោះទ្វារ ។ លុះបានឃើញបុរសនោះចេញមកក្រៅ ត្រៀមខ្លួនប្រព្រឹត្តអាក្រក់ ព្រះអង្គ صلوات الله عليه والسلام និយាយជាមួយបុគ្គលនោះយ៉ាងផ្អែមល្ហែមថា៖





ដឹងថាខ្លួនមិនមែនអ្នកណាក្រៅពីចោរប្លន់អំណាច អាប់ឌុល-ម៉ាលិក ប៊ិន ម៉ារវ៉ានបារម្ភខ្លាំងអំពីវត្តមានរបស់អ៊ីម៉ាំអាស់សាច្ជ់យ៉ាដ្ជ صلوات الله عليه والسلام ។ អាប់ឌុល-ម៉ាលិកបានឃ្លាំមើលអ៊ីម៉ាំ صلوات الله عليه والسلام យ៉ាងតឹងរ៉ឹងជានិច្ច ក្នុងអំឡុងរជ្ជកាលរបស់ខ្លួន ។ អភិបាលក្រុងម៉ាឌីណាស្ដ់បានទទួលបញ្ជាឲ្យលួចយកការណ៍ពីព្រះអង្គ صلوات الله عليه والسلام និងត្រួតពិនិត្យទំនាក់ទំនងរបស់ព្រះអង្គ صلوات الله عليه والسلام យ៉ាងហ្មត់ចត់បំផុត ។

ការរឹតបន្តឹងនេះឥតប្រយោជន៍ទេ ព្រោះអ៊ីម៉ាំអាស់សាច្ជ់យ៉ាដ្ជ صلوات الله عليه والسلام ដឹងថាជំនាន់ឪពុករបស់អាប់ឌុល-ម៉ាលិក គ្រាន់បើជាងជំនាន់របស់អាប់ឌុល-ម៉ាលិក ហើយព្រះអង្គ صلوات الله عليه والسلام ដឹងថាកាលពីមុន អ៊ីម៉ាំអាល់-ហ៊ូសែន صلوات الله عليه والسلام មិនបានទទួលការគាំទ្រគ្រប់គ្រាន់ទេ ដើម្បីរំលំរបបមិនស្របច្បាប់របស់ពួកអ៊ូម៉ៃយ៉ាស្ដ់ ទោះបីព្រះសាស្ដា صلى الله عليه وآله وسلم មិនបានចាកចោលពួកមុស្លីមយូរប៉ុន្មានទេក៏ដោយ ព្រះអង្គ صلوات الله عليه والسلام ច្បាស់ជានឹងទទួលបរាជ័យដូចគ្នាដែរបើព្រះអង្គ صلوات الله عليه والسلام ប្រថុយកែប្រែសង្គមឬនយោបាយពេលនេះ ។ នៅក្នុងបរិយាកាសប្រកបដោយការភ័យខ្លាចពួកអ៊ូម៉ៃយ៉ាស្ដ់ អ៊ីម៉ាំ صلوات الله عليه والسلام សម្រេចចិត្តស្រោចស្រង់អ្វីដែលអាចស្រោចស្រង់បាន គឺៈ ថែរក្សាគោលសាសនាអ៊ីស្លាមពីការបំភ្លៃគាឡៃ និងរាំងដំណើរការបំផ្លិចបំផ្លាញសាសនាពិតរបស់អល់ឡោះហ្វ់ عز وجل ស្រដៀងដំណើរការដែលបានធ្វើឲ្យខូចសាសនារបស់អ៊ីសា عليه السلام និងព្រះ

ប្រទេសស៊ីរីមួយ ។

ប៊ិន អាស់ស៊ុ្បៃរ៍បានសោយរាជ្យអស់មួយទសវត្សរ៍ ។ ក្រោយពីនោះ អ៊ាប់ឌុល-ម៉ាលិក (عبد الملك) កូនរបស់ម៉ារវ៉ាន បានវាយយកម៉ាក់កាស់បានសម្រេចបន្ទាប់ពីបានបំផ្លិចបំផ្លាញស្រុកនេះទាំងស្រុង រួមទាំងកាក់បាស់ដែរដោយបាញ់នឹងដង្ហក់ ។ មេបញ្ជាការចម្បាំងកំណាចរូបនេះជាឧក្រិដ្ឋជនល្បីម្នាក់ឈ្មោះហាជ់យ៉ាជ់ (الحجاج) ។ ក្រោយពីនោះហាជ់យ៉ាជ់ត្រូវបានតែងតាំងជាអភិបាលដែនដីអ៊ីស្លាមខាងកើត ចាប់ពីអ៊ីរ៉ាក់ទៅ ហើយហាជ់យ៉ាជ់ជាមេឃាតកររបស់មូស្លីមស្មោះត្រង់ដែលបានបះបោរ និងដែលមានភក្តីភាពចំពោះអាស់លុល-បៃត៍ عليهم السلام ។

ក្នុងរជ្ជកាលរបស់អាស់ស៊ុ្បៃរ៍និងក្នុងរជ្ជកាលរបស់អ៊ាប់ឌុល-ម៉ាលិក ប៊ិន ម៉ារវ៉ាន អ៊ីម៉ាំអាស់សាជ់យ៉ាដ់ صلوات الله عليه والسلام បានដកព្រះកាយឆ្ងាយពីការប្រយុទ្ធដណ្តើមអំណាច ហើយបានលះបង់ព្រះកាយដើម្បីថែរក្សានិងការពារអ៊ីស្លាមពិតប្រាកដឲ្យបានរួចផុតពីភាពវៀចវេរ ។

## អ៊ីម៉ាំនិងអ៊ាប់ឌុល-ម៉ាលិក



«ប្អូនអើយ ប្អូនឯងបានថាដាក់ខ្ញុំ صلوات الله عليه والسلام អ្វីដែលប្អូនឯងបានថា ។ បើអ្វីដែលប្អូនឯងបានថានោះជាការពិត សូមឲ្យអល់ឡោះហ៍ عز وجل អត់ទោសឲ្យខ្ញុំ صلوات الله عليه والسلام បើវាមិនពិតទេ សូមឲ្យអល់ឡោះហ៍ عز وجل អត់ទោសឲ្យប្អូនឯង ។» បុរសរូបនោះរំភើបណាស់ គាត់បានមកជិតអ៊ីម៉ាំ صلوات الله عليه والسلام ដើម្បីសូមទោស សូមឲ្យព្រះអង្គ صلوات الله عليه والسلام កុំប្រកាន់ទោសពៃរ៍ ។

មូហាំម៉ាដ់ ប៊ិន អ៊ូសាម៉ាស់ កូនរបស់សាវ័កម្នាក់របស់ព្រះសាស្តាឌ៏ចបានធ្លាក់ខ្លួនឈឺ ។ អ៊ីម៉ាំ صلوات الله عليه والسلام បានទៅលេងគាត់ ។ ឃើញគាត់យំ អ៊ីម៉ាំ صلوات الله عليه والسلام បានសួរកេមូលហេតុទុក្ខរបស់គាត់ ហើយបានដឹងថាគាត់ជំពាក់គេជាទម្ងន់ ។ អ៊ីម៉ាំ صلوات الله عليه والسلام ក៏បានសងបំណុលគាត់អស់ឥតរួញរាឡើយ ។

នេះគ្រាន់តែជាឧទាហរណ៍តូចមួយដែលសឲ្យឃើញថា អ៊ីម៉ាំ صلوات الله عليه والسلام មានតួនាទីសង្គមកិច្ច ។ មែន តម្រាប្រវត្តិសាស្ត្រទាំងអស់បានចែងប្រាប់យើងថាព្រះអង្គ صلوات الله عليه والسلام ជាទីពឹងពាក់របស់គ្រួសារទាល់ក្រទាំងឡាយ នៃស្រុកម៉ាឌីណាស់ ថារៀងរាល់យប់ព្រះអង្គ صلوات الله عليه والسلام លីបាវធំមួយដើរចែកជំនួយនិងស្បៀងឲ្យជនទាល់ក្រទាំងឡាយ ពីផ្ទះមួយទៅផ្ទះមួយ មិនមានអ្នកណាម្នាក់មើលព្រះអង្គ صلوات الله عليه والسلام ស្គាល់ទេ ។ លុះព្រះអង្គ صلوات الله عليه والسلام ចូលទិវង្គតពេលលែងមានការផ្តល់ស្បៀងនិងជំនួយ ទើបពួកគេដឹងការពិតនិងដឹង





មូអ៊ុាវីយ៉ាស់ ប៊ិន យ៉ាស៊ីដជាមុស្លីមស្មោះត្រង់ ។ គាត់បានច្រានចោលដូនតាគាត់និងបទឧក្រិដ្ឋទាំងឡាយរបស់ដូនតាគាត់ ហើយបានប្រកាសថាគាត់មិនជាប់ពាក់ព័ន្ធទោសជាមួយអំពើទាំងឡាយ ដែលដូនតាគាត់បានប្រព្រឹត្តនោះទេ ។ គាត់បានបោះបង់ចោលអំណាច បណ្ដាលឲ្យមានចន្លោះនយោបាយជាគ្រាដំបូងបង្អស់ក្នុងប្រវត្តិត្រកូលអ៊ូម៉ៃយ៉ាស់ ។

ក្នុងចន្លោះពេលនេះ អ៊ុាប់ឌុលឡោះហ៍ ប៊ិន អាស់ស៊ូបៃរ៍ (عبد الله بن الزبير) បានតាំងខ្លួនជាខ៊័លិហ្វនៅនគរម៉ាក់កាស់ ហើយអាចក្ដាប់ខ៊័លីហ្វាស់មុស្លីមទូទៅបាន លើកលែងតែដាម៉ាស់និងតំបន់ក្បែរដាម៉ាស់ព្រោះម៉ារ៉្វាន ប៊ិន អាល់-ហ៊ាកាំ (مروان بن الحكم) បានតាំងខ្លួនជាខ៊័លិហ្វរបស់ដែនដីទាំងនេះហើយទទួលបាននូវការគាំទ្រពីសំណាក់អតិជនស៊ីរីទាំងអស់ ។

នៅគូហ្វាស់ អាល់-មុក្ខតារ (المختار) មុស្លីមបដិវត្តបុគ្គល បានដណ្ដើមអំណាចដើម្បីសងសឹកឲ្យអ៊ីម៉ាំអាល់-ហ៊ូសែន៍ صلوات الله عليه والسلام និងបណ្ដាសាវករបស់ព្រះអង្គ صلوات الله عليه والسلام បានចាប់ខ្លួនបាននិងបានសម្លាប់ពួកដែលបានចូលរួមក្នុងការកាប់សម្លាប់ទិវាអាស្ហ៊ូរ៉អ៊ុំមួយចំនួនច្រើន ។

ទ័ពរបស់ប៊ិន អាស់ស៊ូបៃរ៍បានបង្ក្រាបកុបកម្មរបស់អាល់-មុក្ខតារ ។ ពិភពលោកអ៊ីស្លាមទូទៅនៅក្រោមអំណាចរបស់ប៊ិន អាស់ស៊ូបៃរ៍ លើកលែងតែ

អាល់-ហ៊ូសែន៍ صلوات الله عليه والسلام នោះម៉្លេះ លះបង់ចោលព្រះអង្គ صلوات الله عليه والسلام នៅពេលផ្តាច់ព្រ័ត្រនៃប្រវត្តិសាស្រ្តអ៊ីស្លាម ។

មិនរង់ចាំយូរទេ បុគ្គលកាន់អំណាចផ្តាច់ការនៃនគរដ្វាម៉ាស់បានតបតការបះបោរនេះដោយចាត់បញ្ជូនឧក្រិដ្ឋជនសង្គ្រាមម្នាក់ ដែលធ្លាប់បានបម្រើឪពុកបុគ្គលកាន់អំណាចផ្តាច់ការរូបនេះមកហើយកាលពីមុន ដោយបានប្រព្រឹត្តការកាប់សម្លាប់យ៉ាងច្រើននៅឯប្រទេសយេមេន ។ យ៉ាស៊ីដបានជ្រើសរើសយកឧក្រិដ្ឋជនរូបនេះ ដើម្បីបំពេញបេសកកម្មអាក្រក់បំផុតក្នុងប្រវត្តិសាស្រ្តអ៊ីស្លាមគឺៈ វាយយកស្រុករបស់ព្រះសាស្តា صلى الله عليه وآله وسلم សម្លាប់រហ៍ពលរបស់ព្រះអង្គ صلوات الله عليه والسلام រំលោភស្រ្តីនិងប្លន់យកទ្រព្យសម្បត្តិរបស់ពួកគេ ។ ប្រវត្តិសាស្រ្តបានប្រាប់ឲ្យដឹងតួលេខគួរឲ្យតក់ស្លុត មនុស្សប្រាំបីពាន់នាក់ត្រូវកាប់សម្លាប់ក្នុងមួយថ្ងៃគត់ ។

## សម័យអស្ថិរភាពនយោបាយ

យ៉ាស៊ីដបានសោយរាជ្យអស់បួនឆ្នាំ ។ មូអាវីយ៉ាស់ កូនរបស់យ៉ាស៊ីដ បានឡើងកាន់អំណាចបន្ទាប់ពីយ៉ាស៊ីដបានស្លាប់ ។



អត្តសញ្ញាណរបស់ឧបការីរបស់ពួកគេ ។

អ្នកប្រវត្តិសាស្រ្តដែលគួរឲ្យទុកចិត្តបានឲ្យដឹងថា ចំនួនគ្រួសារដែលនៅក្រោមបន្ទុកអ៊ីម៉ាំអាស់សាច់យ៉ាដ់ صلوات الله عليه والسلام ក្នុងនគរម៉ាឌីណាស់ មានចំនួនលើសពី ១០០ គ្រួសារដែលរបបអយុត្តិធម៌អ៊ូម៉ៃយ៉ាស់មិនយកចិត្តទុកដាក់ ។ បើគេដឹងថាអាកប្បកិរិយាប្រកបដោយសប្បុរសធម៌របស់អ៊ីម៉ាំ អាស់សាច់យ៉ាដ់ ចំពោះសេចក្តីលំអៀងក្នុងវិស័យសង្គមកិច្ច ក្នុងសម័យដែលព្រះអង្គ صلوات الله عليه والسلام ទទួលរងអំពើអយុត្តិធំបំផុតក្នុងប្រវត្តិសាស្រ្ត ពោលគឺ ការកាប់សម្លាប់មិត្តនិងក្រុមគ្រួសារព្រះអង្គ صلوات الله عليه والسلام ជាមួយព្រះបិតា صلوات الله عليه والسلام ព្រះអង្គ صلوات الله عليه والسلام អ៊ីម៉ាំអាល់-ហ៊ូសែន៍ صلوات الله عليه والسلام នៅឯការបាឡាអ៊ំ (كربلاء) គេច្បាស់ជានឹងដឹងថាវិញ្ញាណថ្លៃថ្នូរខ្ពង់ខ្ពស់មួយដួងនេះមិនមានដើមកំណើតមកពីណាឡើយ ក្រៅពីមកពីបុគ្គលសុក្រឹតឥតខ្ចោះ ដែលមិនមានគំនុំនិងសេចក្តីទន់ជ្រាយ ។

នេះគឺអ៊ីម៉ាំអាស់សាច់យ៉ាដ់ صلوات الله عليه والسلام ។ ដើម្បីយល់ឲ្យបានច្បាស់នូវលក្ខណៈសំខាន់នៃគុណសម្បត្តិរបស់ព្រះទាយាទថ្លៃថ្នូររបស់អ៊ីម៉ាំអាល់-ហ៊ូសែន៍ صلوات الله عليه والسلام យើងត្រូវឆ្លងកាត់ការបាឡាអ៊ំ និងព្រឹត្តិការណ៍ដែលបានកើតឡើងក្រោយមក ។

# នៅពីមុខការកាប់សម្លាប់នៅការបាឡាអ៊ុំ

អ៊ីម៉ាំអ៊ាលី អាស់សាច់យ៉ាដ្ជ័ صلوات الله عليه والسلام បានទៅតាមព្រះបិតាព្រះអង្គ صلوات الله عليه والسلام អ៊ីម៉ាំអាល់-ហ៊ូសែន صلوات الله عليه والسلام ក្នុងការធ្វើដំណើរចុងក្រោយរបស់ព្រះអង្គ صلوات الله عليه والسلام ពីនគរម៉ាឌីណាស្វ័ទៅកាន់នគរម៉ាក់កាស្វ័ បន្ទាប់ពីនោះ ពីនគរម៉ាក់កាស្វ័ទៅកាន់ការបាទ្បាអ៊ុំ ស្រុកដែលក្រុមគ្រួសាររបស់ព្រះនត្តារបស់ព្រះសាស្តា صلى الله عليه وآله وسلم ត្រូវគេកាប់សម្លាប់នៅចំពោះមុខព្រះអង្គ صلوات الله عليه والسلام ដោយមិនអាចចូលរួមក្នុងការតស៊ូបានទ្បើយ ។

មែន អល់ឡោះហ៊ូ عز وجل មានព្រះបំណងថែរក្សាទឡ្ហការី صلوات الله عليه والسلام របស់ព្រះអង្គ عز وجل ពីសត្វលោកទាំងឡាយរបស់ព្រះអង្គ عز وجل ដោយមិនឲ្យគេរិះគន់ព្រះអង្គ صلوات الله عليه والسلام ថ្ងៃណាមួយ ឬចោទព្រះអង្គ صلوات الله عليه والسلام ជាមិនមានសេចក្តីក្លាហាន ។ ដូច្នេះ អ៊ីម៉ាំអ៊ាលី អាស់សាច់យ៉ាដ្ជ័ صلوات الله عليه والسلام កាលនៅពីមុខការប្រយុទ្ធ កាលកំពុងប្រយុទ្ធ និងកាលក្រោយការប្រយុទ្ធ ព្រះអង្គ صلوات الله عليه والسلام ត្រូវជម្ងឺបៀតបៀនជាទម្ងន់ មិនអាចងើបឈរបានឬមិនអាចកាន់អាវុធបានទ្បើយ ។ ដូច្នេះពេលដែលគេកំពុងប្រយុទ្ធ អ៊ីម៉ាំ صلوات الله عليه والسلام មិនចេញពីពន្លាព្រះអង្គ صلوات الله عليه والسلام បានទ្បើយ ។ ទោះបីព្រះអង្គ صلوات الله عليه والسلام ព្យាយាមចាកចេញពីពន្លាព្រះអង្គ صلوات الله عليه والسلام ក៏ដោយ





ឯង ? បើអ្នកឯងជាជាជីតារបស់អ្នកឯង អ្នកឯងនិយាយកុហក ។ បើអ្នកឯងជាជាជីតារបស់ខ្ញុំ صلوات الله عليه والسلام ហេតុអ្វីអ្នកឯងសម្លាប់គ្រួសាររបស់ព្រះអង្គ صلى الله عليه وآله وسلم និងបណ្ដាកូនចៅរបស់ព្រះអង្គ صلى الله عليه وآله وسلم ?»

បានស្ដាប់សុន្ទរកថារបស់អ៊ីម៉ាំអាស់សាជ្ជ៉ាដ صلوات الله عليه والسلام ហើយ ភ្ញៀវទាំងឡាយរន្ធត់ និងក្រោធចំពោះបទឧក្រិដ្ឋរបស់បុគ្គលកាន់អំណាចផ្ដាច់ការអ៊ូម៉ៃយ៉ាស់ ។ ភ្ញៀវមួយចំនួនបានចាកចេញពីម៉ាស់ជ្ជិដ ។

ខ្លាចសំណាក់មុស្លីមនៃប្រទេសស៊ីរីបះបោររំដើបរំដួល គឺសំណាក់មុស្លីមដែលធ្លាប់តែជាបក្សគ្រួរឲ្យទុកចិត្តរបស់ខ្លួនរហូតមកដល់ពេលនេះ យ៉ាស៊ីដ បានបញ្ជាឲ្យបញ្ជូនពួកអ្នកទោសទៅឯលំនៅដ្ឋានពួកគេវិញ នៅឯម៉ាឌីណាស់ ។ តែរឿងកាប់សម្លាប់នៅឯការបាឡាអ៍បានសាយភាយ រាលដាលពាសពេញពិភពលោកអ៊ីស្លាមហើយ ។ ជាពិសេសអ្នកស្រុកម៉ាឌីណាស់មានទុក្ខខ្លាំងជាងគេ ។

ព្រោះតែខ្លាចបាត់បង់កិត្តិយស ម៉ាឌីណាស់បានបះបោរ និងបានបដិសេធពួកអ៊ូម៉ៃយ៉ាស់និងបទឧក្រិដ្ឋនានារបស់ពួកគេ ។ ការបះបោរប្រឆាំងនេះជាការប៉ុនប៉ងស្ដារកិត្តិយសឡើងវិញ កិត្តិយសដែលបានបាត់បង់ទៅហើយតាំងពីថ្ងៃដែលនគរនេះបានបដិសេធ មិនព្រមចូលរួមក្នុងការបះបោររបស់អ៊ីម៉ាំ



ស៊ៃណាប់ سلام الله عليها ព្រះបិតុច្ឆា (ម្ដាយមីង) ព្រះអង្គ صلوات الله عليه والسلام បានឃាត់ព្រះអង្គ صلوات الله عليه والسلام ព្រោះព្រះនាងប្រតិបត្តិតាមបង្គាប់តឹងរ៉ឹងរបស់អ៊ីម៉ាំអាល់-ហ៊ូសែន صلوات الله عليه والسلام ព្រះរៀមរបស់ព្រះនាង ។ អ៊ីម៉ាំអាល់-ហ៊ូសែន صلوات الله عليه والسلام បានប្រាប់ព្រះនាងថា ទោះជាការប្រយុទ្ធនៅក្នុងស្ថានភាពណាក៏ដោយ ព្រះរាជបុត្រព្រះអង្គ صلوات الله عليه والسلام អ៊ាលី អាស់សាជ្ជ៉ាដ صلوات الله عليه والسلام ត្រូវតែចាកផុតទុក្ខភ័យជាចាំបាច់ ដើម្បីផ្សព្វផ្សាយព្រះរាជសារពិតប្រាកដរបស់អល់ឡោះហ៊ូ عزّ وجلّ តទៅមុខទៀត ។

## ជាមួយឈ្លើយសឹក

ថ្ងៃអ៊ាស៊្ហូរ៉អ៍ (عاشوراء) បន្ទាប់ពីអ៊ីម៉ាំអាល់-ហ៊ូសែន صلوات الله عليه والسلام និងបណ្ដាសាវកទាំងអស់របស់ព្រះអង្គ صلوات الله عليه والسلام បានបូជាជីវិត អ៊ីម៉ាំស៊ៃនុល-អ៊ាប៊ីឌីន អាស់សាជ្ជ៉ាដ صلوات الله عليه والسلام ត្រូវជាប់ឃុំជាមួយស្រីៗនិងក្មេងៗទាំងអស់ ។

គេបាននាំខ្លួនអ៊ីម៉ាំ صلوات الله عليه والسلام ទៅដោយដាក់ច្រវាក់ លើដំនិះ ព្រោះព្រះអង្គ صلوات الله عليه والسلام ឈឺធ្ងន់មិនអាចដើរបានទេ ។ ព្រះអង្គ صلوات الله عليه والسلام ត្រូវធ្វើដំណើរក្នុងអាការធ្ងន់ធ្ងរនេះពីការបាឡាអ៍ទៅគូហ្វាស់ (الكوفة) ដោយមានឈាមហូរពីមុខរបួសលើកព្រះអង្គ صلوات الله عليه والسلام បណ្ដាលមកពីមុតច្រវាក់ ។





អាស់លុល-បៃត៍នៅក្នុងម៉ាស់យ៊ិដធំ ដោយមានវត្តមានរបស់ប្រជារាស្ត្រស៊ីរីយ៉ាងច្រើននិងភ្ញៀវនានាដែលត្រូវចាត់បញ្ជូនមកពីគ្រប់តំបន់ ដែលនៅក្រោមខិលីហ្វាស់របស់ខ្លួន ។

មិនយូរប៉ុន្មាន ការប្រជុំដ៏អធិកអធមនេះបានក្លាយទៅជារឿងអាស្រូវមួយសម្រាប់យ៉ាស៊ីដ ពេលអ៊ីម៉ាំអាស់សាច់យ៉ាដ់ صلوات الله عليه والسلام បានថ្លែងនៅលើវេទិកាម៉ាស់យ៊ិដនូវសុន្ទរកថាមួយដែលដិតជាប់នៅក្នុងអារម្មណ៍ ដោយសារតែភ្ញៀវទាំងឡាយបានដាក់សម្ពាធលើយ៉ាស៊ីដ ។ នៅក្នុងសុន្ទរកថានេះ អ៊ីម៉ាំ صلوات الله عليه والسلام បានរំលឹកភ្ញៀវឲ្យដឹងឡើងវិញថាព្រះអង្គ صلوات الله عليه والسلام ជាអ្នកណា ហើយព្រះបុព្វការី عليهم السلام របស់ព្រះអង្គ صلوات الله عليه والسلام ជាអ្នកណា លុះដល់ការកាប់សម្លាប់នៅឯការបាឡាអ៍ ដោយបើកឲ្យឃើញនូវអំណាចមិនស្របច្បាប់របស់យ៉ាស៊ីដ ។

យ៉ាស៊ីដឃើញថាព្រឹត្តិការណ៍មិនល្អសម្រាប់ខ្លួន ក៏បានបញ្ជាឲ្យគេប្រកាសបំពេញនមស្ការដើម្បីបញ្ឈប់សុន្ទរកថារបស់អ៊ីម៉ាំអាស់សាច់យ៉ាដ់ صلوات الله عليه والسلام តែអ៊ីម៉ាំ صلوات الله عليه والسلام បានថ្លែងបន្តសុន្ទរកថាព្រះអង្គ صلوات الله عليه والسلام ដោយអត្ថាធិប្បាយពីលើការប្រកាសនមស្ការ ។ ពេលព្រះអង្គ صلوات الله عليه والسلام បានឮគេថា៖ «ខ្ញុំសូមប្ដេជ្ញាថាមូហាំម៉ាដ់ជាព្រះសាស្ដារបស់អល់ឡោះហ៍» ព្រះអង្គ صلوات الله عليه والسلام បានបែរទៅរកយ៉ាស៊ីដហើយសួរថា៖ «មូហាំម៉ាដ់ម្នាក់នេះជាជីតាខ្ញុំ صلوات الله عليه والسلام ឬជាជីតារបស់អ្នក

ព្រះអង្គ ﷺ នឹងមានព្រះវចនៈថាអ្វីខ្លះ ? »

ពួកដែលចូលគាល់មួយចំនួនធំបានហូរទឹកភ្នែក ។ នៅក្រោមសម្ពាតជនទាំងនេះ យ៉ាស៊ីដបានបញ្ជាឲ្យគេដោះចំណងពីអ្នកទោស ។

ត្រេកត្រអាលនឹងជ័យជំនះបញ្ឆោត យ៉ាស៊ីដបានបង្ហើបឲ្យដឹងនូវចម្លើយសារភាពច្បាស់ទែងនិងពុតត្បុតរបស់ខ្លួន ។ ព្រមនឹងវាយព្រះកេសអ៊ីម៉ាំអាល់-ហ៊ូសែន صلوات الله عليه والسلام ដែលគេបានយកមកឲ្យក្នុងថាសមាស យ៉ាស៊ីដបានសូត្រកំណាព្យពីរបីឃ្លា ដែលមានសេចក្ដីបញ្ជាក់ប្រាប់ជនទាំងឡាយដែលមានវត្តមាននៅទីនោះថាខ្លួនទើបនឹងបានសងសឹកសមរភូមិបាដារ (بدر) ឯរឿងរ៉ាវរវាងពួកបានី-អ៊ូម៉ៃយ៉ាស់ និងពួកបានី-ហាស្ស៊ីមនោះជាការប្រយុទ្ធតតួដើម្បីអំណាចដែលខ្លួនទើបនឹងបានឈ្នះជាស្ថាពរ ។

អ្នកប្រវត្តិសាស្ត្រដែលគួរឲ្យជឿបានបានធ្វើសេចក្ដីរាយការណ៍ថា ព្រះអគ្គនារីស៊ែណាប់ سلام الله عليها បានឆ្លើយតបយ៉ាស៊ីដវិញយ៉ាងក្លោះក្លាយ ដោយមានពាក្យសំអាងគ្រប់គ្រាន់ ដើម្បីធ្វើឲ្យបុគ្គលរូបនេះបាត់បង់នូវភាពស្របច្បាប់នៅចំពោះមុខជនទាំងឡាយដែលជឿអល់ឡោះហ៍ عز وجل និងព្រះសាស្ដា ﷺ ព្រះអង្គ عز وجل ។

ស្ថិតនៅក្នុងវិបត្តិស្មារតី យ៉ាស៊ីដគិតថាគប្បីធ្វើពិធីបុណ្យឆ្លងជ័យជំនះលើ



នៅក្បែរគូហ្វាស់ ពួកអ្នកស្រុកបានចេញមកជួបឈ្លើយសឹក ។ អ៊ីម៉ាំ صلوات الله عليه والسلام បានឆ្លៀតយកឱកាសនេះដើម្បីរំលឹកដល់អំពើក្បត់របស់ពួកគេ ដល់ការក្បត់កិច្ចសន្យានិងពាក្យសម្បថម៉ឺងម៉ាត់របស់ពួកគេ ដែលពួកគេបានធ្វើនិងបានសរសេរផ្ញើទៅឲ្យព្រះបិតា صلوات الله عليه والسلام ព្រះអង្គ صلوات الله عليه والسلام ។ ហ្វូងមនុស្សមិនមានពាក្យឆ្លើយតបទេក្រៅពីបង្ហូរទឹកភ្នែក ដោយខំប្រឹងបិទបាំងសេចក្ដីកំសាករបស់ខ្លួន តែឥតប្រយោជន៍ទេ ។ សេចក្ដីកំសាកដែលបានធ្វើឲ្យពួកគេលែងជាទីពឹងពាក់របស់អ៊ីម៉ាំអាល់-ហ៊ូសែន صلوات الله عليه والسلام សេចក្ដីកំសាកដែលបានឃាត់ពួកគេ មិនឲ្យតស៊ូទល់ពួកឃាតកររបស់អ៊ីម៉ាំអាល់-ហ៊ូសែន صلوات الله عليه والسلام ។

## នៅឯវាំងអភិបាលក្រុង

ឈ្លើយសឹកត្រូវនាំខ្លួនទៅជួប អ៊ីបនូ ស៊ីយ៉ាដ់ អភិបាលក្រុងគូហ្វាស់ ។ បុគ្គលអសទ្ធា សាហាវឃោរឃៅនិងគុំគួនរូបនេះស្មានថានឹងបានឃើញកូនចៅរបស់ព្រះសាស្ដា ﷺ បាក់មុខនិងអាប់ឱន ក្រោយពីបានទទួលរងការបាត់បង់សាច់ញាតិ ការធ្វើទារុណកម្មនិងការដាក់ច្រវាក់ ។ តែផ្ទុយស្រឡះពីការស្មាន អភិបាលក្រុងគូហ្វាស់បានឃើញនៅពីមុខខ្លួននោះនូវអតិជនមិនរញេម

ដែលប្រកបដោយសេចក្ដីក្លាហាន គឺអតិជនដែលទុក្ខវេទនាក្នុងលោកនេះមិនអាចកម្ចាត់កិត្តិយសបាន ឬអាចធ្វើឲ្យបាត់បង់ភាពថ្លៃថ្នូរបានឡើយ ។ ពេលបានឃើញអ៊ីម៉ាំអាស់សាជ្ជ៉ាដ صلوات الله عليه والسلام អភិបាលក្រុងបានសួរព្រះអង្គ صلوات الله عليه والسلام ទាំងភ្ញាក់ផ្អើលថា៖

-ឯងឈ្មោះអ្វី ?

-ខ្ញុំ صلوات الله عليه والسلام ឈ្មោះ អ៊ុាលី صلوات الله عليه والسلام បុត្ររបស់ អាល់-ហ៊ូសែន صلوات الله عليه والسلام ។

អ៊ីបនូ ស៊ីយ៉ាដបាននិយាយដោយព្យាបាទនិងក្រអឺតក្រទមថា៖

-អល់ឡោះហ៊ូ عز وجل មិនបានសម្លាប់កូនរបស់អាល់-ហ៊ូសែន صلوات الله عليه والسلام ទេឬ ?

-ខ្ញុំមានបងប្រុសម្នាក់ឈ្មោះអ៊ុាលី អាល់-អាក់បារ ។ មនុស្សបានសម្លាប់គាត់ ។

-អល់ឡោះហ៊ូ عز وجل ទេជាអ្នកសម្លាប់គាត់ ។

-អល់ឡោះហ៊ូ عز وجل ទទួលយកព្រលឹងពេលមនុស្សស្លាប់ ។ ទាល់តែអល់ឡោះហ៊ូ عز وجل អនុញ្ញាតទើបមនុស្សអាចស្លាប់បាន ។ (ស៊ូ.៣៩ អា.៤២)

អ៊ីម៉ាំ صلوات الله عليه والسلام បានឆ្លើយតបវិញ ដោយមិនយកចិត្តទុកដាក់នឹងកំហឹងដែលកំពុងតែដុតកោលអ៊ីបនូ ស៊ីយ៉ាដព្រោះតែចាញ់សម្ដីឈ្លើយសឹកម្នាក់ ។ ចាល់សម្ដី អ៊ីបនូ ស៊ីយ៉ាដបានបញ្ជាឲ្យពេជ្ឈឃាតពិឃាដអ៊ីម៉ាំ صلوات الله عليه والسلام ។



បៃត៍) ។» បុរសចំណាស់បានលាន់មាត់ដោយភ្ញាក់ផ្អើលថា៖ «សូមអល់ឡោះហ៊ូ عز وجل ជាសាក្សី ។ ប្រាប់ខ្ញុំមកថាអស់លោកជាអាស់ហ្លុល-បៃត៍មែនទេ ?» អ៊ីម៉ាំ صلوات الله عليه والسلام មានវចនៈថា៖ «មែន សូមស្បថចំពោះព្រះសាស្ដា صلى الله عليه وآله وسلم ព្រះអយ្យកោ صلى الله عليه وآله وسلم យើង ។ ពិតជាយើងមែន ។» បុរសចំណាស់បានស្ទុះទៅឱបអ៊ីម៉ាំ صلوات الله عليه والسلام ហើយស្រែកថា៖ «ទូលបង្គំសូមប្រានទោលពួកដែលបានសម្លាប់ព្រះអង្គ عليهم السلام ទាំងឡាយ ។» ឃើញថាបុរសចំណាស់នេះអាចធ្វើឲ្យមនុស្សទូទៅភ្ញាក់ខ្លួន ដឹងហុសឡើងវិញ ហើយអាចក្លាយទៅជាការបះបោរធំមួយ យ៉ាស៊ីដបានបញ្ជាឲ្យគេសម្លាប់បុរសចំណាស់នេះ ។

## អ៊ីម៉ាំ صلوات الله عليه والسلام តទល់យ៉ាស៊ីដ

យ៉ាស៊ីដ បុរសកំណាច បានបញ្ជាឲ្យគេនាំអ្នកទោសអាស់ហ្លុល-បៃត៍ចូលមកដោយចងជើងនិងដៃគួរឲ្យអាណោចអាធ័មណាស់ ។ លុះអ៊ីម៉ាំអាស់សាជ្ជ៉ាដ صلوات الله عليه والسلام បានចូលមកក្នុងសាល ព្រះអង្គ صلوات الله عليه والسلام បានស្រែកដាក់មុខយ៉ាស៊ីដឥតញញើតថា៖ «យ៉ាស៊ីដ អ្នកឯងយល់យ៉ាងណា បើព្រះសាស្ដា صلى الله عليه وآله وسلم ព្រះអយ្យកោ صلى الله عليه وآله وسلم ខ្ញុំ صلوات الله عليه والسلام ឃើញយើង عليهم السلام នៅក្នុងសភាពបែបនេះ ។ តើ

ចំពោះសម្ដីគាត់ ។ ព្រះអង្គ صلوات الله عليه والسلام បានប្រាប់គាត់ថា៖

- « ព្រឹទ្ធាចារ្យអើយ លោកបានសូត្រគួរអានទេ ? »

- « បានសូត្រ ។ »

- « លោកបានសូត្រព្រះបន្ទូលអល់ឡោះហ៍ عز وجل ទេ គឺ៖ “ខ្ញុំមិនសូមឈ្នួលពីអស់លោកក្នុងរឿងនេះទេ ខ្ញុំសូមឲ្យតែអស់លោកអាណិតស្រឡាញ់បណ្ដាសាច់ញាត់សាលោហិតរបស់ខ្ញុំតែប៉ុណ្ណោះ [៤២:២៣]” និងព្រះបន្ទូលព្រះអង្គ عز وجل “ចូរអ្នកប្រគល់ឲ្យទៅបណ្ដាសាច់ញាតិជិតស្និទ្ធរបស់អ្នកនូវអ្វីដែលពួកគេត្រូវបាន [១៧:២៦]” និងព្រះបន្ទូលព្រះអង្គ عز وجل “អ្វីៗទាំងអស់ដែលពួកអ្នកបានយកជាទ្រព្យឈ្លើយនោះ មួយភាគប្រាំនៃអ្វីទាំងនោះជាកម្មសិទ្ធិរបស់អល់ឡោះហ៍ របស់សាស្ដានិងរបស់សាច់ញាតិ[របស់សាស្ដា] [៨:៤១] ? »

បុរសចំណាស់បានទូលថា៖ « ខ្ញុំបានសូត្រអ្វីទាំងនេះហើយ ។ » អ៊ីម៉ាំ صلوات الله عليه والسلام មានវចនៈថា៖ « អាយ៉ាស់ទាំងនេះចែងផ្ដោតមកលើយើងនេះឯងដែលជាសាច់ញាតិនោះ ។ » ហើយអ៊ីម៉ាំ صلوات الله عليه والسلام បានបន្ថែមថា៖ « “សមាជិកនៃគេហដ្ឋាន[របស់សាស្ដា]អើយ អល់ឡោះហ៍គ្រាន់តែប្រាថ្នាឲ្យពួកអ្នកចាកផុតពីមន្ទិល ហើយប្រាថ្នាជម្រះបន្សុទ្ធពួកអ្នកឲ្យជ្រះស្អាតតែប៉ុណ្ណោះទេ [៣៣:៣៣] ។” ចូរលោកដឹងថាយើងគឺសមាជិកនៃគេហដ្ឋាន(អាស់លុល-





អគិនារី ស្ហៃណាប់ سلام الله عليها បានស្ទុះទៅស្ទាក់មុខអ៊ីម៉ាំ صلوات الله عليه والسلام ព្រះភាគិនេយ្យ (ក្មួយប្រុស)ព្រះនាង និងពេជ្ឈឃាតព្រះអង្គ صلوات الله عليه والسلام ហើយបានស្រែកដាក់មុខ អ៊ីបនូ ស៊ីយ៉ាដ្ឋថា៖ «អ៊ីបនូ ស៊ីយ៉ាដ្ឋ អ្នកឯងបានបង្ហូរឈាមយើងគ្រប់គ្រាន់ហើយ ។ បើអ្នកឯងចង់សម្លាប់គេ صلوات الله عليه والسلام ចូរសម្លាប់យើង سلام الله عليها មុនទៅ ។»

មិនតក់ស្លុត អ៊ីម៉ាំអាស់សាជ្ជ៉ាដ صلوات الله عليه والسلام បានស្រដីដាក់បុគ្គលសាហាវយង់ឃ្នងថា៖ «អ្នកឯងមិនដឹងទេឬថាយើងស៊ាំនឹងឃាតកម្មហើយ ។ សម្រាប់អល់ឡោះហ៊្វ عز وجل ជោគជ័យធំរបស់យើងគឺទុក្ករកម្ម (ការបូជាជីវិតដើម្បីអល់ឡោះហ៊្វ عز وجل) ?»

នៅពីមុខមហាជន ដែលមានសុទ្ធតែអ្នកមានមុខមាត់ក្នុងតំបន់នេះ អ៊ីបនូ ស៊ីយ៉ាដ្ឋ កញ្ជ្រោងសម្បូរល្បិច យល់ហេតុការណ៍ថាយកល្អគួរដកឈើយសឹកទាំងនេះចេញ ជាជាងទទួលខុសត្រូវចំពោះការពិឃាដពួកគេយ៉ាងកំសាកនៅក្នុងវាំងរបស់ខ្លួន ។ អ៊ីបនូ ស៊ីយ៉ាដ្ឋបានបញ្ជាឲ្យបញ្ជូនឈើយសឹកទៅឲ្យយ៉ាស៊ីដ្ឋ ម្ចាស់របស់ខ្លួនដែលនៅឯស្រុកដ្ឋាម៉ាស់ គាត់ក្តីខ្លួនឯង ។

## ទៅកាន់ដ្ឋាម៉ាស់



តាមផ្លូវទៅកាន់ដ្ឋាម៉ាស់ អ៊ីម៉ាំ صلوات الله عليه والسلام និងមិត្តទាំងឡាយរបស់ព្រះអង្គ صلوات الله عليه والسلام បានរងអំពើឃោរឃៅគ្រប់យ៉ាងពីសំណាក់ពេជ្ឈឃាត ដែលអមពួកគេ ។ ពួកគេមិនត្រឹមតែដើរឲ្យគេឃើញក្រោមកម្តៅថ្ងៃក្តៅថែស ក្នុងរដូវក្តៅប៉ុណ្ណោះទេ តែពួកអ្នកយាមថែមទាំងបានទទួលបញ្ជាឲ្យពួកគេដើរកាត់តាមស្រុកទាំងអស់នៃប្រទេសស៊ីរី ដើម្បីឲ្យពួកអ្នកស្រុកបានឃើញនូវអំណាចរបស់ស្តេចពួកគេ និងដើម្បីកំញើញពួកមុស្លីម កុំឲ្យពួកគេប៉ងបះបោរ ។ ម្យ៉ាងទៀត យ៉ាស៊ីដ្ឋ បុរសកំណាច បានដាក់បញ្ជាឲ្យតុបតែងស្រុកដ្ឋាម៉ាស់និងតំបន់ជិតខាង និងឲ្យប្រកាសធ្វើពិធីបុណ្យទូទៅ ។

ក្រោយយុទ្ធនាការបង្ខូចកេរ្តិ៍ឈ្មោះអាស់លុល-បៃត៍ដ៏ធំ រៀបចំដោយប្រព័ន្ធឃោសនារបស់សំណាក់អ៊ូម៉ៃយ៉ាស្ទ ប្រជារាស្ត្រស្រុកដ្ឋាម៉ាស់បានចេញមកក្រៅស្រុកដើម្បីមើលក្បួនហែឈើយសឹក ។ លុះបានឃើញអ៊ីម៉ាំ ស៊្ហៃនុល-អាប៊ីឌីន អាស់សាជ្ជ៉ាដ صلوات الله عليه والسلام ជាប់ច្រវាក់ បុរសចំណាស់ម្នាក់បានចូលមកជិតព្រះអង្គ صلوات الله عليه والسلام ហើយបានថា៖ «សូមគោរពសក្ការៈអល់ឡោះហ៊្វ عز وجل ដែលបានកម្ទេចពួកអ្នកឯង ហើយបានបញ្ចុះបញ្ចូលពួកអ្នកឯងក្រោមអំណាចស្តេចយើង ។» អ៊ីម៉ាំអាស់សាជ្ជ៉ាដ صلوات الله عليه والسلام យល់ភ្លាមថាបុរសចំណាស់នេះជាអ្នករងគ្រោះយុទ្ធនាការឃោសនាបង្ខូចឈ្មោះ ហើយគាត់ជឿជាក់